## ជំនួយសំរាប់ជនរងគ្រោះដោយឧក្រិដ្ឋកម្ម

ឧក្រិដ្ឋកម្មប៉ះពាល់ដល់ជនរងគ្រោះតាមរបៀបផ្សេងៗ។ ក្នុងនាមជាជនរងគ្រោះដោយឧក្រិដ្ឋកម្ម អ្នកប្រហែលជាមានអារម្មណ៍ផ្លាស់ប្តូរខុសពីមុន។ អ្នកប្រហែលជាមាន អារម្មណ៍ថាគ្មាននរណាអាចជួយអ្នកបាន គេដទៃទៀតបានបោះបង់អ្នកចោល ហើយមានអារម្មណ៍ថាគ្មាននរណាម្នាក់យល់នូវអ្វីដែលអ្នកកំពុងឆ្លងកាត់នេះទេ។ អ្នកប្រហែលជាមានអារម្មណ៍ថា អ្នកបានបាត់បង់នូវសុវត្ថិភាពនិងសន្តិសុខ។ អ្នកប្រហែលជាជួបប្រទះនឹងមនោសញ្ចេតនាដែលច្របូកច្របល់។ មានមធ្យោបាយផ្សេងៗក្នុងការទ្រាំទ្រនឹងឧក្រិដ្ឋកម្ម ហើយនិងរបៀបដែលអ្នកមានអារម្មណ៍ក្នុងនាមជាជនរងគ្រោះ។ អ្នកប្រហែលជា:

- អនុញ្ញាតអោយខ្លួនឯងមាននូវថ្ងៃល្អនិងថ្ងៃមិនល្អ;
- ធ្វើកិច្ចការល្អសំរាប់ខ្លួនឯង;
- ចៀសវាងធ្វើការសំរេចចិត្តធំៗ រហូតទាល់តែមានអារម្មណ៍គ្រាន់បើឡើងវិញ;
- បរិភោគនិងធ្វើការហាត់ប្រាណបានល្អ;
- និយាយអំពីអារម្មណ៍របស់អ្នក។

មានការបំរើដើម្បីជួយជនរងគ្រោះដោយឧក្រិដ្ឋកម្ម បន្ថែមទៅលើគ្រួសារនិងមិត្តភ័ក្តិរបស់អ្នក។

### អង្គការយុត្តិធម៌សំរាប់ជនរងគ្រោះ

ប៉ូលិសរដ្ឋអូស្ត្រាលីខាងត្បូង

មន្ត្រីសំរាប់អោយជនរងគ្រោះធ្វើការទាក់ទង

ទូរស័ព្ទ 8207 5000

ទាយកផ្តន្ទាទោសសាធារណ:

ផ្នែកជំនួយសាក្សី

ទូរស័ព្ទ 8207 1529

រដ្ឋអំណាចរដ្ឋបាលតុលាការ

តំបន់ទីក្រុង ទូរស័ព្ទ 8204 2444

តំបន់ជនបទ

សូមទូរស័ព្ទទៅតុលាការប្រចាំតំបន់

ក្រសួងកសាងអ្នកទោស

ផ្នែកបំរើជនរងគ្រោះ ទូរស័ព្ទ 8226 9067

គណៈកម្មការសំរេចការដោះលែងអ្នកទោសដោយមានលក្ខខ័ណ្ឌ មុនពេលកំណត់ត្រូវដោះលែង ទូរស័ព្ទ 8224 2555

សំណងជម្ងឺចិត្តចំពោះរបួសដោយឧក្រិដ្ឋកម្ម

ក្រសួងអគ្គមេធាវី ទូរស័ព្ទ 8207 1694

រដ្ឋអំណាចរដ្ឋបាលតុលាការ ទូរស័ព្ទ 8204 0287

### អង្គការគាំទ្រជនរងគ្រោះ

ជំនួយទៅពេលមានវិបត្តិ ទូរស័ព្ទ 13 1 6 11 (ក្រៅម៉ោងធ្វើការ)

Lifeline ទូរស័ព្ទ 13 11 14 (២៤ម៉ោង)

អង្គការបំរើវិបត្តិហិង្សាទៅក្នុងគ្រួសារ

ទូរស័ព្ទ 8223 2200 (ពេលម៉ោងការិយាល័យធ្វើការ)

ទូរស័ព្ទជំនួយហិង្សាទៅក្នុងគ្រួសារ

ទូរស័ព្ទ 1800 800 098 (២៤ម៉ោង)

អង្គការជំនួយជនរងគ្រោះ

តំបន់ទីក្រុង ទូរស័ព្ទ 8231 5626

តំបន់ជនបទ ទូរស័ព្ទ 1800 182 368 ឬ

អង្គការជំនួយជនរងគ្រោះ នៅ Port Lincoln, Port Augusta, Port Pirie, Berri ឬ Mount Gambier

Yarrow Place (អង្គការបំរើផ្នែករំលោភ និង វាយរំលោភផ្នែកភេទ)

តំបន់ទីក្រុង ទូរស័ព្ទ 8226 8777

តំបន់ជនបទ ទូរស័ព្ទ 1800 817 421

អង្គការបំរើ Ethnic Link Services

ទូរស័ព្ទ 8241 0201 (ពេលម៉ោងការិយាល័យធ្វើការ)

មជ្ឈមណ្ឌលផ្គត់ផ្គង់ Migrant Resource Centre

Adelaide ទូរស័ព្ទ 8223 3604

Salisbury ទូរស័ព្ទ 8250 8606

ក្រសួងបកប្រែភាសាតាមទូរស័ព្ទ ទូរស័ព្ទ 13 14 50

### ជនរងគ្រោះដោយឧក្រិដ្ឋកម្មមានសិទ្ធិ

គេត្រូវប្រព្រឹត្តិមកលើអ្នកដោយមានការគួរសម គោរពនិងសេចក្តីអាណិតអាសូរ ហើយនិងគិតពិចារណាដល់អាយុ ភេទ ពូជសាសន៍ឬជាតិពន្ធ ប្រវត្តវប្បធម៌ឬភាសារបស់អ្នក។

ប្រសិនបើអ្នកគិតថា អ្នកត្រូវការអោយគេការពារ ដើម្បីអោយផុតពីអ្នកប្រព្រឹត្តិបទល្មើសនោះ អ្នកអាចប្រាប់ទៅប៉ូលិសអោយបានដឹងអំពីកង្វល់របស់អ្នកនៅពេលតុលាការកំពុងស្តាប់អ្នកល្មើសច្បាប់នោះសុំចេញនៅក្រៅឃុំ។ អ្នកគួរប្រាប់ទៅប៉ូលិស ប្រសិនបើអ្នកមានកង្វល់ណាមួយអំពីសន្តិសុខរបស់អ្នក។ ប៉ូលិសឬមន្ត្រីតុលាការនឹងប្រាប់អ្នកអំពីលទ្ធផលនៃការដាក់ពាក្យសុំនៅក្រៅឃុំរបស់អ្នកល្មើសច្បាប់ ប្រសិនបើអ្នកសួរ។

អ្នកអាចស្នើសួរពតិមានអំពីការស៊ើបអង្កេត បទល្មើសហើយនិងថ្ងៃដែលត្រូវឡើងតុលាការ ដូចជា ពេលម៉ោងនិងកាលបរិច្ឆេទ។ នៅពេលដែលប៉ូលិសបានចោទអ្នកណាម្នាក់ហើយនោះ អ្នកអាចស្នើសួរអំពីឈ្មោះរបស់អ្នកនោះបាន។

អ្នកអាចស្នើសួរដើម្បីអោយគេប្រាប់អ្នកវិញ ប្រសិនបើផ្នែកផ្តន្ទាទោសសំរេចថានឹងមិនធ្វើការចោទ ផ្លាស់ការចោទឬទទួលយកការសារភាពថាបានធ្វើបទល្មើសដែលស្រាលបន្តិច។

គេមិនគួរស្នើអោយអ្នកទៅតុលាការស្តាប់ទម្រង់ការបណ្តឹងណាមួយទេ លុះត្រាតែកិច្ចការនោះសំខាន់ហើយអ្នកត្រូវតែទៅ។

ប្រសិនបើច្បាប់តម្រូវអោយអ្នកទៅតុលាការក្នុងនាមជាសាក្សី នោះគេគួរប្រាប់អ្នកអំពីរបៀបវិនិច្ឆ័យទោស ហើយនិងសិទ្ធិព្រមទាំងទំនួលខុសត្រូវ

របស់អ្នកក្នុងនាមជាសាក្សី។

នៅពេលដែលអាចធ្វើទៅបាននោះ គេគួរតែការពារអ្នកអោយផុតពីទំនាក់ទំនងដែលមិនចាំបាច់ជាមួយនឹងអ្នកល្មើសច្បាប់ ឬ សាក្សីណាមួយរបស់អ្នកល្មើសច្បាប់នៅក្នុងកំឡុងពេលតុលាការធ្វើការវិនិច្ឆ័យទោស។

អ្នកនឹងមិនត្រូវអោយអាស័យដ្ឋានរបស់អ្នកទៅតុលាការទេ លើកលែងតែវាសំខាន់សំរាប់ការផ្តន្ទាទោសឬក្នុងរឿងដោះសារការចោទរបស់គេ។ វាគួរតែគ្មានការឈ្លានពានដែលមិនចាំបាច់ដល់ភាពឯកជនរបស់អ្នក។

អ្នកអាចធ្វើសេចក្តីថ្លែងការមួយអំពីរបួស ការបាត់បង់ឬខូចខាតណាមួយដែលជាលទ្ធផលនៃបទល្មើសនេះ។ នៅក្នុងករណីយ៍ខ្លះ ក្រសួងផ្តន្ទាទោសនឹងអោយសេចក្តីថ្លែងការរបស់អ្នកទៅតុលាការ មុនពេលតុលាការកាត់ទោស។ នៅក្នុងករណីយ៍ដទៃខ្លះទៀត អ្នកឬអ្នកណាម្នាក់ដែលតំណាងអ្នកអាចមានសិទ្ធិអានសេចក្តីថ្លែងការរបស់អ្នកចំពោះតុលាការ មុនពេលតុលាការធ្វើការកាត់ទោស។

គេគួរអោយអ្នកនូវពត៌មានស្តីអំពីសំណងជម្ងឺចិត្ត ហើយប្រសិនបើក្រសួងផ្តន្ទាទោសបានទទួលសេចក្តីអនុញ្ញាតធ្វើការដាក់ពាក្យសុំសំណងជម្ងឺចិត្តជំនួសអ្នក នោះក្រសួងនេះគួរធ្វើតាមសំណើររបស់អ្នក។

កម្មសិទ្ធិណាមួយរបស់អ្នកដែលគេយកសំរាប់ទៅធ្វើការស៊ើបអង្កេត ឬ ប្រើជាភស្តុតាងនោះ គួរបញ្ជូនមកអោយអ្នកវិញនៅពេលណាដែលអាចធ្វើទៅបាន ហើយទោះបីយ៉ាងណាក៏ដោយ គេមិនគួរទុកកម្មសិទ្ធិទាំងនោះយូរជាងការចាំបាច់ឡើយ។

អ្នកក៏អាចសួរពត៌មានស្តីអំពីការកាត់ទោសណាមួយដែលគេដាក់អោយជនល្មើស ហើយនិងលទ្ធផលនៃការឡើងទៅតុលាការអំពីការដោះលែងអ្នកទោសដោយមានលក្ខខ័ណ្ឌមុនពេលកំណត់ត្រូវដោះលែង។

ប្រសិនបើអ្នកបាននិយាយជាមួយនឹងបុគ្គលិកនៅឯផ្នែកបំរើជនរងគ្រោះនៃក្រសួងកសាង គេគួរប្រាប់អ្នកប្រសិនបើជនល្មើសនោះបានគេចមុនពេលធ្វើការវិនិច្ឆ័យទោស លួចរត់ចេញពីមន្ទីរឃុំឃាំង (ឬត្រូវគេចាប់បានវិញ) ឬ ប្រសិនបើអ្នកជនល្មើសនោះនឹងត្រូវបានគេដោះលែងអោយរស់នៅក្នុងសហគម។

មុនពេលគេដោះលែងជនល្មើសនោះ អ្នកអាចធ្វើសេចក្តីថ្លែងការជាលាយល័ក្ខអក្សរមួយទៅគណៈកម្មការដោះលែងអ្នកទោសដោយមានលក្ខខ័ណ្ឌមុនកំណត់ត្រូវដោះលែង។ សេចក្តីថ្លែងរបស់អ្នកអាចចុះសរសេរពត៌មានដែលនឹងជួយគណៈកម្មការនេះធ្វើការសំរេចចិត្តថា តើលក្ខខ័ណ្ឌអ្វីខ្លះដែលត្រូវដាក់អោយជនល្មើសនោះ ឧទាហរណ៍ មិនអោយជននោះមកផ្ទះឬកន្លែងការងាររបស់អ្នក។

ប្រសិនបើអ្នកមានបណ្តឹងណាមួយអំពីរបៀបដែលគេប្រព្រឹត្តិមកលើអ្នក ឬ អំពើអយុត្តិធម៌ណាមួយនោះ គេនឹងប្រាប់អ្នកអំពីទម្រង់ការដែលមានសំរាប់ដោះស្រាយបណ្តឹងរបស់អ្នក ប្រសិនបើអ្នកស្នើ។

---

ពត៌មានបន្ថែម សូមមើលទៅគេហប្រពន្ធ:
Victims of Crime Co-ordinator's website at
http://www.voc.sa.gov.au

**លេខរបស់អ្នក សំរាប់ធ្វើការទាក់ទងនឹងប៉ូលិស**

សូមរក្សាទុកពត៌មាននេះ

ពត៌មាននេះអាចអោយអ្នកទាក់ទងនឹងប៉ូលិស ប្រសិនបើអ្នកត្រូវការពត៌មានអំពីករណីយ៍របស់អ្នក។

ចំពោះសំណួរណាមួយ សូមទាក់ទងនឹង

..........................................................................

ទូរស័ព្ទ..................................................................

លេខរបាយការណ៍របស់អ្នកគឺ:

..........................................................................

ហត្ថលេខា...............................................................

លេខឋានន្តរសក្តិ.........................................................

ថ្ងៃទី.......................................................................

ខែឧសភា ឆ្នាំ២០០២

KHMER

# ពត៌មាន សំរាប់ជនរងគ្រោះ ដោយឧក្រិដ្ឋកម្ម

## Information for Victims of Crime

ក្រសួងអគ្គមេធាវី
រដ្ឋអូស្ត្រាលីខាងត្បូង